**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ០៥ សរណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២

## I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២

### ក- *ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច*

១- បន្ទាប់ពីសម្រេចបាននូវកំណើនខ្ពស់ (ជាមធ្យមជាង ៩%) រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងរក្សាបានអត្រាអតិផរណាទាប(ក្រោម៥%)ព្រមទាំងគ្រប់គ្រង និងកសាងបាននូវស្ថានភាពហិរញ្ញវត្ថុសាធារណៈប្រកបដោយការប្រុងប្រយ័ត្ន និងភាពជឿទុកចិត្តបាន ដែលបានធ្វើឱ្យកម្រិតជីវភាពរស់នៅរបស់ប្រជាជនមានការរីកចម្រើន (ផសស ក្នុងមនុស្សម្នាក់កើនឡើង ២ ដង) និងអត្រាភាពក្រីក្រត្រូវបានថយចុះជាង ១% ក្នុងមួយឆ្នាំ ជិតមួយទសវត្សមក (ពីឆ្នាំ ២០០០ ដល់ ២០០៧) សេដ្ឋកិច្ចកម្ពុជាត្រូវបានទទួលរងនូវផលប៉ះពាល់នៃវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ នឹងឱនភាពសេដ្ឋកិច្ចសកលលោកយ៉ាងធ្ងន់ធ្ងរ ដែលចាប់ផ្តើមពីពាក់កណ្តាលឆ្នាំ ២០០៨ និងធ្លាក់ដល់បាតនៅឆ្នាំ ២០០៩ ។ ទន្ទឹមនឹងនេះ កម្ពុជាក៏ត្រូវបានរងនូវវិបត្តិព្រំដែន គ្រោះធម្មជាតិ និងអត្រាអតិផរណាខ្ពស់ថែមទៀតផង ។ ទោះជាយ៉ាងណា ដោយសារការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ គោលនយោបាយហិរញ្ញវត្ថុប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ និងគោលនយោបាយរូបិយវត្ថុដ៏សមស្រប គួបផ្សំនឹងការអប្បមាទជាប្រចាំ និងដាក់ចេញនូវវិធានការប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា គឺមិនត្រឹមតែធ្វើឱ្យកម្ពុជាអាចទប់ទល់នឹងវិបត្តិទាំងនោះបានដោយជោគជ័យប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាអាចងើបឡើងវិញយ៉ាងឆាប់រហ័សគឺក្នុងទម្រង់ជាអក្សរវេ " V " នៅឆ្នាំ ២០១០ ដែលតាមការគណនារបស់វិទ្យាស្ថានជាតិស្ថិតិ កំណើនសេដ្ឋកិច្ចសម្រេចបាន ៥,៩% គឺដោយសារវិស័យកសិកម្មមានកំណើន ៤% វិស័យឧស្សាហកម្មមានកំណើន ១៣,៥% និង វិស័យសេវាកម្មមានកំណើន ៣,១% ។

២- តាមការព្យាករណ៍ដោយប្រយ័ត្នប្រយែង និងដោយផ្អែកលើលទ្ធផលត្រីមាសទី ១ និងនិន្នាការសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក សេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០១១ អាចនឹងមានកំណើនប្រមាណ ៦% ដូចដែល

បានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។ កំណើននេះនឹងបានមកដោយសារវិស័យកសិកម្មនឹងបន្តមានកំណើនប្រមាណ ៤,១% ក្នុងនោះផលិតផលស្រូវនឹងមានកំណើនប្រមាណ ៤,១% និងផលិតផលជលផល នឹងមានកំណើនប្រមាណ ៤,៣% ។ ទន្ទឹមនឹងការសង្ឃឹមលើកំណើនផលិតកម្មស្រូវ ដែលជាផ្លែផ្កានៃការអនុវត្តគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ មួយផ្នែកទៀតនឹងបានមកពីកំណើនផលិតកម្មកៅស៊ូ និង ដំឡូងមី ដែលបាន និងកំពុងមាននិន្នាការកើនឡើង ។ វិស័យឧស្សាហកម្មអាចនឹងមានកំណើន ៩,២% ក្នុងនោះផ្នែកវាយនភ័ណ្ឌនឹងមានកំណើនប្រមាណ ១១,២% និងផ្នែកសំណង់នឹងមានកំណើនប្រមាណ ៦,៧% ។ ទន្ទឹមនឹងនេះ ការវិនិយោគលើផ្នែកផ្គុំដំឡើង និងការរុករករ៉ែ និងវារីអគ្គិសនី ដែលបាន និងកំពុងចាប់ផ្តើមដំណើរការអាជីវកម្ម នឹងរួមចំណែកក្នុងការជំរុញកំណើននៃវិស័យនេះបន្ថែមទៀត ។ វិស័យសេវាកម្មអាចនឹងមានកំណើនប្រមាណ ៥,៧% ក្នុងនោះផ្នែកទេសចរណ៍នឹងមានកំណើនប្រមាណ ១២,៨% ។ ទន្ទឹមនឹងនេះ ការចាប់ផ្តើមងើបឡើងវិញនៃផ្នែកអចលនវត្ថុ និងផ្នែកធនាគារ និងហិរញ្ញវត្ថុ នឹងរួមចំណែកជំរុញកំណើនក្នុងវិស័យនេះបន្ថែមទៀត ។

៣- ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ គឺស្ថិតក្នុងបរិការណ៍ដែលសេដ្ឋកិច្ចតំបន់ និងពិភពលោកកំពុងងើបឡើងចេញពីវិបត្តិក៏ពិតមែន តែហានិភ័យ និងបញ្ហាប្រឈមថ្មីក៏បាន និងកំពុងកើតឡើងផងដែរ ដូចជាសម្ពាធនៃអត្រាអតិផរណាដែលរាលដាលចេញពីការឡើងថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារ ទៅដល់បណ្តាទំនិញដទៃទៀត និងការប្រែប្រួលនៃលំហូរមូលធនដែលអាចកើតឡើងដោយសារការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុ ។ សម្រាប់ឆ្នាំ ២០១២ តាមការ ព្យាករណ៍ កំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបានក្នុងរង្វង់ ៦,៥% ។ វិស័យកសិកម្មនឹងបន្តរក្សាកំណើនក្នុងរង្វង់ ៤,២% ក្នុងនោះផលិតផលស្រូវនឹងមានកំណើនប្រមាណ ៤,៤% និងផលិតផលជលផល នឹងមានកំណើន ប្រមាណ ៣,៩% ។ ទន្ទឹមនឹងនេះ ថ្លៃនៃកសិផលមួយចំនួនបាន និងកំពុងមាននិន្នាការកើនឡើង ដូចជា ស្រូវ ដំឡូងមី ស្វាយចន្ទី ពោត និងកៅស៊ូជាដើម ដែលជាសក្តានុពលរួមចំណែកជំរុញកំណើននៃវិស័យនេះ ។ វិស័យឧស្សាហកម្មអាចនឹងមានកំណើន ៩,៤% ក្នុងនោះផ្នែកវាយនភ័ណ្ឌអាចនឹងមានកំណើនប្រមាណ ១១,២% ពិសេសដោយសារការនាំចេញទៅសហគមន៍អឺរ៉ុបអាចនឹងកើនឡើងក្រោមកម្មវិធី «ទំនិញគ្រប់មុខ លើកលែងតែសព្វាវុធ» និង ផ្នែកសំណង់អាចនឹងមានកំណើនប្រមាណ ៩,៣% ។ ទន្ទឹមនឹងនេះ គម្រោង វិនិយោគថ្មីៗ លើផ្នែកអគ្គិសនី (វារីអគ្គិសនី និងអគ្គិសនីដើរដោយធ្យូងថ្ម) រ៉ែ និងឧស្សាហកម្មធុនស្រាល ដែលបាន និងកំពុងចាប់ផ្តើម នឹងរួមចំណែកក្នុងការជំរុញកំណើន លើវិស័យនេះថែមទៀត ។ វិស័យសេវាកម្មអាច នឹងមានកំណើនប្រមាណ ៥,៧% ដែលក្នុងនោះផ្នែកទេសចរណ៍អាចនឹងមានកំណើន ៩,៤% ដោយសារតែ ចំនួនភ្ញៀវទេសចរនឹងបន្តកើនឡើងពិសេសភ្ញៀវពីក្នុងតំបន់ ។ ទន្ទឹមនឹងនេះ វិស័យហិរញ្ញវត្ថុអាចនឹងមានសន្ទុះ កើនឡើង ក្នុងពេលដែលទីផ្សារមូលបត្រ នឹងត្រូវបានបង្កើត និងការជំរុញហិរញ្ញប្បទានក្នុងក្របខ័ណ្ឌគោល នយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។ លើសពីនេះ វិស័យអចលនវត្ថុ និងសំណង់ ក៏រំពឹងថា នឹងអាចងើបឡើងវិញផងដែរ ហើយដែលអាចជាសក្តានុពលជំរុញកំណើនក្នុងវិស័យនេះបន្ថែមទៀត ។

៤- អតិផរណានៅកម្ពុជា រងឥទ្ធិពលដោយសារកំណើនថ្លៃម្ហូបអាហារ និង ប្រេងឥន្ធនៈយ៉ាងគំហុកចាប់តាំងពីចុងឆ្នាំ ២០០៧ មក ។ ឥទ្ធិពលនេះ បានធ្វើឱ្យអត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ២០០៨ ឡើងដល់

១៩,៧% ។ ដោយសារការឆ្លើយតបទាន់ពេលវេលា តាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយជាកញ្ចប់ប្រកបដោយប្រសិទ្ធភាព ជាពិសេសការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយការប្រុងប្រយ័ត្នខ្ពស់ និងគោលនយោបាយរូបិយវត្ថុដ៏សមស្រប អត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រូវបានធ្លាក់ចុះមកនៅត្រឹម -០,៦% នៅឆ្នាំ ២០០៩ និង ៤,០% នៅឆ្នាំ ២០១០ ។ ដោយសារអតិផរណាមាននិន្នាការកើនឡើងជាសកល បណ្តាលមកពីការឡើងថ្លៃប្រេង និងម្ហូបអាហារ ថ្លៃវត្ថុធាតុដើម ការបញ្ចេញសាច់ប្រាក់បន្ថែមទៅក្នុងទីផ្សារ និងការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចយ៉ាងគំហុក ពិសេសនៅតំបន់អាស៊ី អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ២០១១ នេះអាចនឹងឡើងដល់ ៥,៥% ធៀបនឹងគោលដៅកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ (៤,៥%) ។

៥- និនភាពគណនីចរន្តមាននិន្នាការធ្លាក់ចុះជាលំដាប់គឺពី -១១,៦% នៃផសស នៅឆ្នាំ ២០០៩ មកត្រឹម -១០,៩% នៃផសស ឆ្នាំ ២០១០ ។ និនភាពគណនីចរន្តនឹងបន្តធ្លាក់ចុះមកនៅត្រឹម -៨,៥% នៅឆ្នាំ ២០១១ និង -៧,៩% នៅឆ្នាំ ២០១២ ។ និន្នាការនៃការធ្លាក់ចុះនេះ គឺដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ គួបផ្សំនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសឱ្យការនាំចូលជាបណ្តើរៗ ។ ទុនបម្រុងអន្តរជាតិបានកើនឡើងពី ២,៤ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៩ ដល់ ២,៦៥ ពាន់លានដុល្លារអាមេរិកនៅឆ្នាំ ២០១០ ។ សម្រាប់ឆ្នាំ ២០១១ និង ២០១២ ទុនបម្រុងអាចកើនឡើងដល់ ឬ អាចលើសពី ២,៨ ពាន់លានដុល្លារអាមេរិក ដែលសមមូលនឹងការនាំចូលប្រមាណជាង ៣ ខែ ។

## ខ- *ស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ថវិកា*

៦- វិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងនិនភាពសេដ្ឋកិច្ចពិភពលោក ពិតជាបានធ្វើឱ្យកំណើនសេដ្ឋកិច្ចនៃបណ្តាប្រទេសជាច្រើនធ្លាក់ចុះរហូតដល់ក្រោមសូន្យ ហើយកំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ ២០០៩ ក៏ត្រូវបានធ្លាក់ចុះយ៉ាងគំហុកផងដែរ តែនៅមានសញ្ញាវិជ្ជមានគឺ ០,១% ធៀបនឹងការព្យាករណ៍ ២,១% ។ ដោយសារការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពប្រុងប្រយ័ត្ន គួបផ្សំនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុសមស្រប កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានងើបឡើងវិញយ៉ាងឆាប់រហ័សគឺសម្រេចបាន ៥,៩% នៅក្នុងឆ្នាំ ២០១០ ។ ប្រការនេះ ពិតជាបានធ្វើឱ្យការអនុវត្តថវិកាឆ្នាំ ២០១០ សម្រេចបានលទ្ធផលយ៉ាងល្អប្រសើរជាងឆ្នាំ ២០០៩ ប្រាកដមែន ។ ជាក់ស្តែង ចំណូលក្នុងស្រុកឆ្នាំ ២០១០ សម្រេចបាន ១០៣,៥% ធៀបនឹងច្បាប់ និងមានកំណើន ១៩,៩% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ហើយស្មើនឹង ១៣,៨១% នៃផសស (ឆ្នាំ ២០០៩ សម្រេចបានតែ ៩៤,៧% នៃច្បាប់ ហើយថយចុះ ៧,៨% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ហើយស្មើនឹង ១១,៩៥% នៃផសស) ។ ចំណូលសារពើពន្ធសម្រេចបាន ៩៨,៥% ធៀបនឹងច្បាប់ និងមានកំណើន ១៣,៨% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ហើយស្មើនឹង ១០,៧៩% នៃផសស (ឆ្នាំ ២០០៩ សម្រេចបានតែ ៩៥,៧% នៃច្បាប់ គឺថយចុះ ៧,២% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ហើយស្មើនឹង ១០,១២% នៃផសស) និង ចំណូលមិនមែនសារពើពន្ធសម្រេចបាន ១២៣,១% ធៀបនឹងច្បាប់ និងមានកំណើន ៨២,៣% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ហើយស្មើនឹង ២,៣៥% នៃផសស (ឆ្នាំ ២០០៩ សម្រេចបានតែ ៩១,១% នៃច្បាប់ គឺថយចុះ ៥,៨% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ហើយស្មើនឹង

១,៧៦% នៃផសស) ។ រីឯការអនុវត្តចំណាយវិញ ទោះជាមានការកើនឡើងលើផ្នែកខ្លះ ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ក៏ដោយ តែជាភាគរយនៃផសសមានការថយចុះ ដោយសារការចាប់ផ្តើមបន្ថយនយោបាយវិត្ថារកម្ម ដើម្បីកាត់បន្ថយឱនភាពថវិកា និងរក្សាស្ថិរភាពហិរញ្ញវត្ថុសាធារណៈ ។ ជាក់ស្តែង ចំណាយសរុបឆ្លងកាត់រតនាគារជាតិអនុវត្តបាន ៩៩,១% នៃច្បាប់ គឺកើនឡើង ៥,៤% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ហើយ ស្មើនឹង ១៤,០៦% នៃផសស ដែលក្នុងនោះ ចំណាយចរន្តអនុវត្តបាន ៩៨,៨% គឺកើនឡើង ៣,៨% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ហើយស្មើនឹង ១១,១១% នៃផសស និង ចំណាយមូលធនសរុបសម្រេចបាន ១០៩,២% នៃច្បាប់ គឺថយចុះ ៧,៨% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ហើយស្មើនឹង ៧,៩៦% នៃផសស ដែលក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេសអនុវត្តបាន ១២៥,២% ធៀបនឹងច្បាប់ គឺកើនឡើង ៣០,៩% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ស្មើនឹង ២,៥៦% នៃផសស រីឯហិរញ្ញប្បទានក្រៅប្រទេសអនុវត្តបាន ១០២,៩% ធៀបនឹងច្បាប់ គឺថយចុះ ១៩,២% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ស្មើនឹង ៥,៣៩% នៃផសស ។ លទ្ធផលនៃការអនុវត្តចំណូល និងចំណាយនេះ បានធ្វើឱ្យមានអតិរេកចរន្ត ២,០២% និងឱនភាពថវិកាសរុប ៥,៦៥% នៃផសស ។ ទន្ទឹមនឹងនេះ ចំណាយតាមវិស័យដែលអនុវត្តបានគឺ វិស័យរដ្ឋបាលទូទៅសម្រេចបាន ១២៤,២% នៃច្បាប់ គឺថយចុះ ០,៥% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ស្មើនឹង ១,៨៨% នៃផសស វិស័យការពារជាតិ និងសន្តិសុខសម្រេចបាន ១០៥,៩% នៃច្បាប់ គឺថយចុះ ១៤,៩% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ស្មើនឹង ២,៦៥% នៃផសស វិស័យសេដ្ឋកិច្ចសម្រេចបាន ៩៦,៩% គឺកើនឡើង ១៦,៦% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ស្មើនឹង ០,៨៨% នៃផសស និងវិស័យសង្គមកិច្ចសម្រេចបាន ៩៧,២% នៃច្បាប់ គឺកើនឡើង ៨,៧% ធៀបនឹងការអនុវត្តឆ្នាំ ២០០៩ ស្មើនឹង ៣,៨៧% នៃផសស ។

៧- តាមការព្យាករណ៍ប្រកបដោយភាពប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចឆ្នាំ ២០១១ នេះ អាចនឹងសម្រេចបានប្រមាណ ៦% ដូចដែលបានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។ ទោះជាយ៉ាងណា ស្ថានភាពនៃការអនុវត្តថវិកាឆ្នាំ ២០១១ នេះ កំពុងជួបការលំបាកដោយសារតែមានតម្រូវការចំណាយចាំបាច់ច្រើន ជាពិសេសការចំណាយសម្រាប់ការងារអធិបតេយ្យភាព និងគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ក្នុងពេលដែលកំណើនចំណូល ចាប់ផ្តើមធ្លាក់ចុះ ធៀបនឹងបណ្តាឆ្នាំមុនៗ ជាពិសេសចំណូលពន្ធដារ ។ ដូច្នេះ ការបន្តពង្រឹងការអនុវត្ត គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពត្រឹមត្រូវ និងប្រុងប្រយ័ត្នខ្ពស់ គួបផ្សំនឹងការជំរុញការកែលម្អ និងការពង្រឹងការប្រមូល និងការគ្រប់គ្រងចំណូល ការកែលម្អ និងការពង្រឹងការអនុវត្ត និងការគ្រប់គ្រងចំណាយ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ២ កាន់តែមានសារៈសំខាន់ និងចាំបាច់ថែមទៀត ដើម្បីធានាឱ្យការអនុវត្តថវិកាឆ្នាំ ២០១១ នេះ ពិសេសការប្រមូលចំណូលអាចសម្រេចបានតាមគោលដៅនៃច្បាប់ហិរញ្ញវត្ថុ ។ តាមការព្យាករណ៍ ចំណូលសរុបអាចនឹងសម្រេចបាន ១០០,៣% នៃច្បាប់ ហើយ បើធៀបទៅនឹងការអនុវត្តឆ្នាំ ២០១០ នឹងកើនឡើង ១៣,៤% ដែលក្នុងនោះ ចំណូលក្នុងស្រុកនឹងសម្រេចបាន ១០០,៤% នៃច្បាប់ នឹងកើនឡើង ១១,១% (ចំណូលសារពើពន្ធនឹងកើន ១៧,៦% និងចំណូលមិនមែនសារពើពន្ធនឹងថយចុះ ១០,៦%) ។ ចំណូលក្នុងស្រុកសរុបអាចនឹងសម្រេចបានប្រមាណ ១៣,៣% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសម្រេចបាន ១១,៣៣% នៃផសស (ក្នុងនោះ ចំណូលគយ

និងរដ្ឋាករស្មើនឹង ៦,១២% និងចំណូលពន្ធដារស្មើនឹង ៨,២៨%) ចំណូលមិនមែនសារពើពន្ធនឹងសម្រេចបាន ១,៨៧% នៃផសស ។ ដោយសារមានតម្រូវការចំណាយចាំបាច់ច្រើន ពិសេសការចំណាយសម្រាប់អធិបតេយ្យភាព និងគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ចំណាយសរុបអាចនឹងកើនឡើងដល់ ១៩,៨៦% នៃផសស គឺកើនឡើង ១៤,៣% ធៀបនឹងការអនុវត្តឆ្នាំ ២០១០ ដែលក្នុងនោះ ចំណាយចរន្តនឹងកើនដល់ ១១% នៃផសស គឺកើនឡើង ១០,៩% ធៀបនឹងឆ្នាំ ២០១០ និងចំណាយមូលធនសរុបអាចនឹងកើនដល់ ៨,៨៦% នៃផសស គឺកើនឡើងប្រមាណ ១៩,១% ធៀបនឹងការអនុវត្តឆ្នាំ ២០១០ ដែលក្នុងនោះ ហិរញ្ញប្បទានក្នុងប្រទេសអាចកើនដល់ ២,៩៧% នៃផសស គឺមានកំណើន ១២,១% ធៀបនឹងការអនុវត្តឆ្នាំ ២០១០ រីឯហិរញ្ញប្បទានក្រៅប្រទេសអាចកើនដល់ ៥,៩០% នៃផសស គឺមានកំណើន ២២,៥% ធៀបនឹងការអនុវត្តឆ្នាំ ២០១០ ។ ការអនុវត្តចំណូល និងចំណាយនេះ អាចនឹងធ្វើឱ្យមានអតិរេកចរន្តប្រមាណ ២,២% នៃផសស និងឱនភាពថវិកាសរុបប្រមាណ ៦,១៦% នៃផសស ។

## II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១២

### *ក. __ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច__*

៨- ពិតណាស់ថាសេដ្ឋកិច្ចនៃបណ្តាប្រទេសមួយចំនួន បានចាប់ផ្តើមងើបឡើងវិញជាបណ្តើរៗតាំងពីចុងឆ្នាំ ២០០៩ ហើយជាក់ស្តែងកំណើនសេដ្ឋកិច្ចនៃបណ្តាប្រទេសភាគច្រើនសម្រាប់ឆ្នាំ ២០១០ និង ២០១១ នេះក៏បាន និងកំពុងបន្តបង្ហាញនូវភាពងើបឡើងវិញយ៉ាងរឹងមាំ និងប្រកបដោយសុទិដ្ឋិនិយមផងដែរ ពិសេសចំពោះបណ្តាប្រទេសនៅអាស៊ី ហើយជាក់ស្តែងកម្ពុជាសម្រេចបាន ៥,៩% និង ៦% បន្ទាប់ពីធ្លាក់ចុះរហូតដល់ ០,១% នៅឆ្នាំ ២០០៩ ។ ឈរលើមូលដ្ឋាននេះ ***កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ក្នុងកម្រិត ៦,៥%*** ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការតាមដាន និងគ្រប់គ្រងសភាពការណ៍ យ៉ាងហ្មត់ចត់ និងជាប្រចាំ ព្រមទាំងបន្តជំរុញការអនុវត្ត ប្រកបដោយភាពទន់ភ្លន់ និងបន្តដាក់ចេញនូវវិធានការថ្មីៗទៀតទៅតាមការវិវត្តន៍នៃស្ថានភាពជាក់ស្តែង ។ ហើយទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលនៅតែប្រកាន់មហិច្ឆតាខ្ពស់ ក្នុងការសម្រេចឱ្យបាននូវគោលដៅកំណើនសេដ្ឋកិច្ចប្រមាណ ៧% និងកាត់បន្ថយភាពក្រីក្រឱ្យបានជាង ១% ក្នុងមួយឆ្នាំៗ ស្របតាមគោលដៅនយោបាយនៃ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** និងដើម្បីបន្តរក្សាឱ្យបាននូវស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលនៅតែជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុត ក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ***ភាពសុខដុមរមនាសង្គម និងសុខុមាលភាពរបស់ប្រជាជន*** ។

៩- ទន្ទឹមនឹងនេះ ហានិភ័យ និងបញ្ហាប្រឈមថ្មីក៏បាន និងកំពុងកើតឡើងផងដែរ ដូចជាសម្ពាធនៃអត្រាអតិផរណាដែលភាគច្រើនចេញពីការឡើងថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារ ទៅដល់បណ្តាទំនិញដទៃទៀត និងការប្រែប្រួលនៃលំហូរមូលធន ដែលអាចកើតឡើងដោយសារការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុ និងបញ្ហាបាត់តុល្យភាពកំណើនរវាងប្រទេសនៅក្នុងតំបន់ និងរវាងតំបន់នៅក្នុងពិភពលោក ។ ដូច្នេះ រាជរដ្ឋាភិបាលនៅតែបន្តពិនិត្យ និងត្រៀមលក្ខណៈប្រើវិធានការគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយហិរញ្ញវត្ថុ

សាធារណៈ ក្នុងករណីចាំបាច់ ដើម្បីគ្រប់គ្រង និងរក្សាអត្រាអតិផរណាក្នុងកម្រិតមួយសមស្រប និងដោយប្រុងប្រយ័ត្នបំផុត ក្នុងគោលដៅកាត់បន្ថយក្នុងកម្រិតអតិបរមានូវផលប៉ះពាល់អាក្រក់លើសេដ្ឋកិច្ចជាតិ និងលើជីវភាពរបស់ប្រជាជន ។ ក្នុងន័យនេះ ទោះជាអត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ២០១១ នេះអាចនឹងឡើងដល់ ៥,៥% ធៀបនឹង ៤,៥% ដែលបានកំណត់ក្នុងច្បាប់ក៏ដោយ ***រាជរដ្ឋាភិបាលនឹងប្រើប្រាស់គ្រប់វិធានការដើម្បីរក្សាអត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ២០១២ ឱ្យនៅក្នុងរង្វង់ ៥%*** ។ ដោយឡែក អត្រាប្តូរប្រាក់មានស្ថិរភាពល្អប្រសើរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គឺស្ថិតក្នុងរង្វង់ ៤១០០ រៀល/ដុល្លារ ដូចបានកំណត់នៅក្នុង **«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣»** ។ ក្នុងបរិការណ៍នៃការធ្លាក់ចុះនៃតម្លៃប្រាក់ដុល្លារអាមេរិក ដើម្បីធានារក្សាឱ្យបាននូវសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា និង ធានារក្សាតុល្យភាពរវាងផលប្រយោជន៍អ្នកមានចំណូលជាប្រាក់រៀល និងអ្នកមានចំណូលជាប្រាក់ដុល្លារអាមេរិក ***រាជរដ្ឋាភិបាលនឹងបន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់នេះ ឱ្យស្ថិតក្នុងរង្វង់ ៤០៥០ រៀល/ដុល្លារ*** តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុសមស្រប ពិសេស គឺការបន្តលើកទឹកចិត្ត និងបង្កើនការប្រើប្រាស់ប្រាក់រៀល ព្រមទាំងជំរុញបដិដុល្លារូបនីយកម្មក្នុងរយៈពេលវែង ។

១០- ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដែលបានកំណត់ខាងលើ នឹងផ្តល់លទ្ធភាពឱ្យរាជរដ្ឋាភិបាល រក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច រក្សាបាននូវកំណើនខ្ពស់ប្រកបដោយចីរភាព រក្សា និងគ្រប់គ្រងបាននូវស្ថិរភាពថ្លៃ ដែលជាមូលដ្ឋានសំខាន់ក្នុងការធានាស្ថិរភាព និងភាពប្រសើរឡើងនៃកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ។ ទន្ទឹមនឹងនេះ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនេះ នឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលបន្តជំរុញការអភិវឌ្ឍតាមវិស័យ ពិសេស ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចដែលត្រូវផ្តោតលើកសិកម្ម កសិ-ឧស្សាហកម្ម និងការអភិវឌ្ឍជនបទ ការអភិវឌ្ឍវិស័យសង្គមកិច្ចដែលត្រូវផ្តោតលើការអប់រំ សុខាភិបាល និងការកសាងធនធានមនុស្ស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលត្រូវផ្តោតលើផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធធារាសាស្ត្រ និងការអភិវឌ្ឍវិស័យឯកជន ។ លើសពីនេះ ក្របខ័ណ្ឌនេះនឹងបង្កលក្ខណៈឱ្យរាជរដ្ឋាភិបាលបន្តជំរុញការអនុវត្តបណ្តាកម្មវិធីកែទម្រង់លើគ្រប់វិស័យ ឱ្យបានកាន់តែស៊ីជម្រៅបន្ថែមទៀត ដែលរួមមានការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់រដ្ឋបាលសាធារណៈ **ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីសម្រេចឱ្យបាននូវការគ្រប់គ្រងរដ្ឋមួយប្រកបដោយអភិបាលកិច្ចល្អ គឺការផ្តល់សេវាសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ។

### ***ខ- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា***

១១- ផ្អែកលើមូលដ្ឋាននៃ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣** ពិសេស ដើម្បីបម្រើឱ្យការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយអភិវឌ្ឍន៍តាមវិស័យ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០១២ មានគោលដៅសំខាន់ៗ ដូចតទៅ ÷

• ធានាឱ្យបាននូវការអនុវត្តគោលបំណងគោលនយោបាយ និងកម្មវិធី/និងយុទ្ធសាស្ត្រអាទិភាពតាមវិស័យនៅក្នុងក្របខ័ណ្ឌនៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ តាមរយៈ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣** ។

• ធានាការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការអភិវឌ្ឍវិស័យអាទិភាព រួមមានវិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍវិស័យឯកជន ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជំរុញកំណើន និងចីរភាពកំណើន ។

• ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំ រំកិល (២០១២-២០១៤) ។

• ធានាបម្រើឱ្យការបន្តសកម្មភាពកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើគ្រប់ផ្នែក ដែលរួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ កំណែទម្រង់វិស័យកងទ័ព និង ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដើម្បីពង្រឹងអភិបាលកិច្ចល្អ និងបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

• ធានាបន្តផ្តល់អាទិភាពដល់បណ្តាវិស័យ ការដ្ឋាន និងសកម្មភាពការងារសំខាន់ៗ រួមមាន ÷

- ***ការបង្កើន និងលើកកំពស់គុណភាពសេវាកម្មនៅក្នុងវិស័យសង្គមកិច្ច*** ជាពិសេស វិស័យ-អប់រំ សុខាភិបាល ការកសាងធនធានមនុស្ស និងសុវត្ថិភាពសង្គម ។
- ***ការបង្កើន និងលើកកំពស់សកម្មភាពដែលបម្រើឱ្យវិស័យសេដ្ឋកិច្ច*** ជាពិសេស វិស័យ-កសិកម្ម ធារាសាស្ត្រ ការអភិវឌ្ឍជនបទ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។
- ***ការងារការពារអធិបតេយ្យភាព និងបូរណភាពទឹកដី ព្រមទាំងការបោះឆ្នោតព្រឹទ្ធសភា និងការបោះឆ្នោតឃុំ-សង្កាត់*** ដើម្បីធានាប្រក្រតីភាពនៃដំណើរការប្រជាធិបតេយ្យភាវូបនីយ-កម្មថ្នាក់មូលដ្ឋាននៅកម្ពុជា ។

១២- ដើម្បីឱ្យក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើអាចសម្រេចបានតាមគោលដៅ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តបណ្តាគោលនយោបាយ និងកម្មវិធីកែទម្រង់សំខាន់ៗ ដូចខាងក្រោម ÷

*ក.* បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធា-រណៈដ៏ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាបន្តសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាពក្នុងបរិការណ៍នៃអត្រាអតិផរណាសមស្រប ។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តអប្បមាទជាប្រចាំ និងត្រៀមដាក់ចេញនូវបណ្តាវិធានការគោលនយោបាយថវិកា ឬ/និង គោលន-យោបាយរូបិយវត្ថុប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងទាន់ពេលវេលា ដើម្បីទប់ទល់ និងគ្រប់គ្រងលើសម្ពាធអតិផរណា និងការប្រែប្រួលនៃលំហូរមូលធន ដែលបាន និងកំពុងរាលដាល និងមានការយកចិត្តទុកដាក់ខ្ពស់នៅក្នុងតំបន់ក៏ដូចជានៅលើសកលលោក ។

*ខ.* បន្តជំរុញការអភិវឌ្ឍតាមវិស័យ ពិសេស វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ។ បន្តជំរុញ និងបង្កើនការលើកស្ទួយវិស័យកសិកម្ម កសិឧស្សាហកម្ម និងជួយគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ពិសេស ជំរុញការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ព្រមទាំងជំរុញ និងលើកទឹកចិត្តដល់ផលិតកម្មនៃបណ្តាកសិផលមួយចំនួនទៀតដែលកំពុងមានសក្តានុពលខ្ពស់ ដូចជា ដំឡូងមី ពោត និងកៅស៊ូ ។ បន្តយកចិត្តទុកដាក់ខ្ពស់លើការបង្កើនគុណភាពសេវាវិស័យអប់រំ សុខាភិបាល និងការកសាងធនធានមនុស្ស ព្រមទាំងការងារបង្កើនសុវត្ថិភាពសង្គម ។ បន្តជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេស ប្រព័ន្ធស្រោចស្រព ព្រមទាំងបន្តបង្កបរិយាកាស និងផ្តល់ការលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យឯកជន ពិសេស ការវិនិយោគក្នុងវិស័យកសិកម្ម និងតាមរយៈយន្តការជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ។

*គ.* បន្តជំរុញការអនុវត្តកំណែទម្រង់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបោសសម្អាតមីន ដោយផ្តោតជាសំខាន់លើការពង្រឹងប្រព័ន្ធគ្រប់គ្រង ការបែងចែកដីធ្លីប្រកបដោយសមធម៌ ការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ក្នុងនោះរួមទាំងដីសម្បទានសេដ្ឋកិច្ច ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការធានាសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លីឱ្យសមស្របតាមច្បាប់ភូមិបាល ដើម្បីជួយគាំទ្រដល់វិស័យកសិកម្ម សំដៅលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម ដើម្បីឱ្យវិស័យនេះក្លាយទៅជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ច ហើយជាបណ្តើរៗឈានទៅកសាងវិស័យឧស្សាហកម្ម ដោយផ្តើមចេញពីឧស្សាហកម្មកែច្នៃកសិផល និងក្នុងគោលដៅធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងបម្រើឱ្យគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

*ឃ.* បន្តពង្រឹង និងពង្រីកប្រព័ន្ធធនាគារ វិស័យធានារ៉ាប់រង ទីផ្សារមូលបត្រ និងទីផ្សារភាគហ៊ុន ក្នុងក្របខ័ណ្ឌនៃការបន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីបង្កើនការគៀរគរធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងបង្កើនសក្តានុពលភាព និងកាលានុវត្តភាពដល់ការធ្វើហិរញ្ញប្បទាន និងការអភិវឌ្ឍវិស័យឯកជន ។

*ង.* បន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ ជាពិសេស បន្តជំរុញការអនុវត្តផែនការសកម្មភាពជំហានទី ២ គឺ ***ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ*** ដោយផ្តោតលើការរៀបចំ និងដាក់ឱ្យអនុវត្តនូវចំណាត់ថ្នាក់ថវិកាថ្មីបន្ថែមទៀត អង្គភាពថវិកា ស្តង់ដារគណនេយ្យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការសាកល្បងការគ្រប់គ្រងហិរញ្ញវត្ថុដោយប្រព័ន្ធព័ត៌មានវិទ្យា ។ ទន្ទឹមនឹងនេះ ***ការបន្តពង្រឹងភាពជឿទុកចិត្តលើថវិកា*** នៃជំហានទី ១ តាមរយៈការបន្តជំរុញការកែលម្អនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីធានាឱ្យការបើកផ្តល់ថវិកាបានទាន់ពេលវេលា ។ ការបន្តកសាង និងកែលម្អក្របខ័ណ្ឌគោលនយោបាយចំណូលរយៈពេលមធ្យមដើម្បីរក្សាស្ថិរភាព និងនិរន្តរភាពចំណូល ពិសេស ផ្តោតការយកចិត្តទុកដាក់លើការកសាង និងពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ យន្តការគ្រប់គ្រង និងការប្រមូលពន្ធ និងអាករ ព្រមទាំងចំណូលមិនមែនសារពើពន្ធ រួមទាំងចំណូលពីធនធានធម្មជាតិផង ។ លើសពីនេះ ត្រូវបន្តជំរុញពង្រឹង និងបង្កើនការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ដែលជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់ ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាបណ្តើរៗ និងដើម្បីឈានទៅ ***បង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*** និង ការ***បង្កើនគណនេយ្យភាពចំពោះសមិទ្ធកម្ម*** ដែលជាគោលដៅនៃជំហានទី ៣ និងទី ៤ ។

*ខ.* បន្តជំរុញ **ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ពិសេស ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាល ច្បាប់ និងលិខិតគតិយុត្តផ្សេងៗ ដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងន័យនេះ **គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)** និង ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវសហការរៀបចំកម្មវិធីសកម្មភាពឱ្យបានច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ជាជំហានៗ ប្រកបដោយភាពហ្មត់ចត់ និងប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានាការអនុវត្តប្រកបដោយភាពរលូន និងប្រសិទ្ធភាព ។ ពិសេស ការពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និងហិរញ្ញវត្ថុរបស់គ្រប់ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ ដើម្បីធានាការផ្ទេរអំណាច និងការទទួលខុសត្រូវពីថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព ។

*គ.* បន្តជំរុញការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការកែលម្អការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ។ ក្នុងន័យនេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវរៀបចំគោលនយោបាយរយៈពេលមធ្យម និងវែង សម្រាប់ការកែលម្អការគ្រប់គ្រងធនធានមនុស្សប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ជាពិសេសត្រូវបង្កើតយន្តការ និងបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យក្របខ័ណ្ឌមន្ត្រីរាជការ ការពង្រឹងការផ្តល់ទិដ្ឋាការឱ្យរើសមន្ត្រីថ្មីបន្ថែមដោយផ្អែកលើការវិភាគលើតម្រូវការជាក់ស្តែង និងលទ្ធភាពថវិកាជាតិ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការចូលនិវត្តន៍ ។ ទន្ទឹមនឹងនេះ ត្រូវពិនិត្យពិចារណាឡើងវិញលើរាល់គោលនយោបាយ និងគោលការណ៍តម្លើង និងផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ រួមទាំងការតម្លើងបៀវត្សមូលដ្ឋានប្រចាំឆ្នាំ ការតម្លើងកាំប្រាក់ ការអនុវត្តប្រាក់បំណាច់មុខងារ ការផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចជា ប្រាក់ម៉ោង ប្រាក់យាម ប្រាក់បេសកកម្ម និងចំណាយប្រតិបត្តិការអាទិភាពជាដើម ដើម្បីធានាសមធម៌ តម្លាភាព សង្គតិភាព និងប្រសិទ្ធភាព ។

*ឃ.* បន្តជំរុញការអនុវត្តកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេស ការពង្រឹងសមត្ថភាពដឹកនាំ វិជ្ជាជីវៈជំនាញ សហប្រតិបត្តិការ និងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ព្រមទាំងការកែសម្រួលរចនាសម្ព័ន្ធកងឯកភាពប្រយុទ្ធ និងការកាត់រំសាយកងទ័ព ដើម្បីធានាការប្រើប្រាស់ និងគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ។

*ឈ.* បន្តជំរុញការអនុវត្តច្បាប់ប្រឆាំងនឹងអំពើពុករលួយ ពិសេស ការបន្តរៀបចំ និងពង្រឹងសមត្ថភាពអង្គភាពប្រឆាំងអំពើពុករលួយដើម្បីអាចដំណើរការ និងប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ក្នុងការអប់រំ ទប់ស្កាត់ និងបោសសម្អាតអំពើពុករលួយ ។

## III. ការគណនា និង ទិតាជន៍ថវិកាឆ្នាំ ២០១២

### ក- <u>គម្រោងចំណាយថវិកា</u>

១៣- ដើម្បីធានាបាននូវការអនុវត្តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ ដែលបានកំណត់ខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ដែលបានគូសបញ្ជាក់មកខាងលើ ថវិកាឆ្នាំ ២០១២ ត្រូវគ្រោងលើមូលដ្ឋានយុទ្ធសាស្ត្រ និងវិធានការដូចខាងក្រោម ÷

- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាសម្ភារៈ និងឧបករណ៍ទំនើបៗ ការជួសជុលធំៗ គ្រឿងសង្ហារិមប្រណិត ព្រមទាំងចំណាយអគ្គិសនី ទូរស័ព្ទ និងប្រេងឥន្ធនៈ ដើម្បី

រក្សាចំណាយសរុបឱ្យស្ថិតនៅក្នុងកម្រិត ១៩,៤២% នៃផសស គឺថយចុះប្រមាណ ០,២៣% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ដែលក្នុងនោះ ចំណាយចរន្តសរុបនឹងត្រូវរក្សាឱ្យនៅត្រឹមប្រមាណ ១១,៤០% នៃផសស និង ចំណាយមូលធននឹងត្រូវរក្សានៅត្រឹមប្រមាណ ៨,០២% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់ ២,០០% នៃផសស និង ឱនភាពថវិកាសរុបក្នុងរង្វង់ ៥,៩១% នៃផសស ។ ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងចំនួន ២,៥២% នៃផសស ក្នុងនោះ ចំណាយសម្រាប់រំលស់បំណុលត្រូវកំណត់ត្រឹម ០,៣៨% នៃផសស។ ដោយឡែក ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវបានគ្រោងក្នុងចំនួន ៥,៥០% នៃផសស ។

- ត្រូវវិភាជន៍ចំណាយចរន្តទៅតាមវិស័យនីមួយៗ ដូចតទៅៈ វិស័យសង្គមកិច្ចស្មើនឹង ៣,៩៧% នៃផសស ថយចុះ ០,១២% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ វិស័យ-សេដ្ឋកិច្ច ០,៨៦% នៃផសស ថយចុះ ០,០៨% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ វិស័យរដ្ឋបាលទូទៅ ១,៣៧% នៃផសស ថយចុះ ០,១២% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ វិស័យការពារជាតិ និងសន្តិសុខ ២,៥០% នៃផសស កើនឡើង ០,០៧% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ និងចំណាយមិនទាន់បែងចែកស្មើនឹង ២,២០% នៃផសស កើនឡើង ០,៤៦% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១។ ថវិការាជធានី- ខេត្ត ត្រូវកំណត់ត្រឹម ០,៦១% ។

១៤- ទន្ទឹមនឹងនេះ ថវិកាឆ្នាំ ២០១២ ត្រូវបន្តបម្រើឱ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ព្រមទាំងការលើកស្ទួយជីវភាពប្រជាជននៅទីជនបទ សំដៅសម្រេចឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ថវិកាឆ្នាំ ២០១២ ត្រូវផ្តល់ការវិភាជជាក់ស្តែងទៅតាមគោលនយោបាយអាទិភាពរបស់វិស័យនីមួយៗ ដោយឆ្លុះបញ្ចាំង ដូចខាងក្រោម៖

- បន្តប្រឹងប្រែងទ្រទ្រង់ថវិកាសម្រាប់វិស័យអប់រំ និង សុខាភិបាល ឱ្យស្របទៅតាមគោលដៅនៃកម្មវិធីចំណាយរយៈពេលមធ្យមសម្រាប់វិស័យអប់រំ និងសុខាភិបាលឆ្នាំ ២០១២- ២០១៤ ។

- បន្តប្រឹងប្រែងទ្រទ្រង់ថវិកាសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ជាពិសេសការកសាង និង ស្តារប្រព័ន្ធស្រោចស្រពគ្រប់ប្រភេទ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយរួមទាំងការថែទាំផ្លូវលំជនបទ ប្រព័ន្ធធារាសាស្ត្រ និងការអភិវឌ្ឍជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញផលិត-កម្មស្រូវ និង ការនាំចេញអង្ករ និង វិស័យសេដ្ឋកិច្ច ដើម្បីកំណើន ការងារ សមធម៌ និង ការកាត់បន្ថយភាពក្រីក្រ ។

- ធានាការពារឱ្យបានទាំងស្រុងនូវអធិបតេយ្យភាពនិងបូរណភាពទឹកដី និងកាតព្វកិច្ចធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន ព្រមទាំងការបោះឆ្នោតព្រឹទ្ធសភា និង ការបោះឆ្នោតឃុំ- សង្កាត់ ដើម្បីធានាប្រក្រតីភាពនៃដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មនៅកម្ពុជា ។

- មូលនិធិថវិកាឃុំ- សង្កាត់ឆ្នាំ ២០១២ ត្រូវកំណត់ស្មើនឹង ២,៨០% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ ២០១១ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

• ថវិកាខេត្ត-ក្រុង ដែលរួមមានថវិកាផ្ទាល់ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិ ហើយដែលនឹងត្រូវក្លាយទៅជាថវិកា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាពេលអនាគតដ៏ខ្លីខាងមុខ នៅពេលដែលរាល់ក្របខ័ណ្ឌគតិយុត្តសម្រាប់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានដាក់ឱ្យអនុវត្ត ហើយរចនាសម្ព័ន្ធរដ្ឋបាល និងមុខងារត្រូវបានកំណត់ និងផ្ទេរចប់សព្វគ្រប់នោះ ត្រូវបន្តអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងរាល់នីតិវិធីដែលមានជាធរមាន ស្របតាមមាត្រា ៨៧ នៃអន្តរប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

• បន្តផ្តល់អាទិភាពនៃការវិភាជន៍ថវិកាដល់ថវិកាកម្មវិធី និង ផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែល បានបញ្ជាក់ពីទិសដៅគោលនយោបាយ គោលបំណង កម្មវិធី និង/ឬ យុទ្ធសាស្ត្រអាទិភាព ផែនការសកម្មភាព ព្រមទាំងលទ្ធផលរំពឹងទុក និងសូចនាករច្បាស់លាស់ ដើម្បីធានាការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងបង្កើនប្រសិទ្ធភាពថវិកា ជាពិសេស ការបន្តពង្រឹង និងការកែលម្អការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ។

## ខ- គម្រោងចំណូលថវិកា

**១៥-** ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃគម្រោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការកសាងគោលនយោបាយចំណូល និងការអនុវត្តឱ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសម្រេចឱ្យបាននូវកម្រិតចំណូលក្នុងស្រុកសរុបប្រមាណ ១៣,៥១% នៃផសស គឺកើនឡើង ០,២៦% នៃផសស និងមានកំណើន ១២,៤% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ដែលក្នុងនោះចំណូលសារពើពន្ធត្រូវសម្រេចឱ្យបាន ១១,៥៤% នៃផសស គឺមានកំណើន ០,៤៣% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឱ្យបាន ១,៨៧% នៃផសស គឺថយចុះ ០,១៦% នៃផសស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ និងចំណូលមូលធនក្នុងស្រុកត្រូវសម្រេចឱ្យបាន ០,១១% នៃផសស ប្រហាក់ប្រហែលនឹងឆ្នាំ ២០១១ ។

**១៦-** ដើម្បីសម្រេចបានតាមគោលដៅនៃការប្រមូលចំណូលសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តជំរុញឱ្យកាន់តែសកម្មថែមទៀតក្នុងការអនុវត្តសកម្មភាពការងារ និងបណ្តាវិធានការទាំងឡាយនៅក្នុងកម្មវិធីសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតលើបណ្តាវិធានការសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

### ទី១- ផ្នែកចំណូលពន្ធដារៈ

- បន្តពង្រឹង និងកែលម្អរដ្ឋបាលពន្ធដារ ពង្រឹងការងារសវនកម្មពន្ធ ពិនិត្យលទ្ធភាពពង្រីកមូលដ្ឋានយកពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និងការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត ។

- បន្តពង្រឹងការអនុវត្តកម្មវិធីកែលម្អរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងប្រតិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ។

- បន្តបញ្ចប់ការកសាង និងចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

- បន្តពង្រឹងការអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ និងឱ្យបានម៉ឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។

- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីក និងពង្រឹងការអនុវត្តរបបពិតនៅតាមបណ្តារាជធានី- ខេត្ត និងបន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។

- បន្តបណ្តុះបណ្តាល និងបង្កើនសមត្ថភាពវិជ្ជាជីវៈ និងសីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និងមធ្យម ។

- បន្តពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេង និងឧស្ម័ន ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេង និងឧស្ម័ន ។

- បន្តធ្វើការសិក្សាអំពីវិចារណកម្មបន្ត និងលទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ និងបណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ។

**ទី២- ផ្នែកចំណូលពន្ធគយ និងរដ្ឋាករ:**

- បន្តជំរុញការរៀបចំតាមការចាំបាច់នៃការងារនូវលិខិតបទដ្ឋាននានា ដើម្បីជំរុញការអនុវត្តច្បាប់ស្តីពីគយ ពិសេសសម្រាប់បន្តកែលម្អបរិស្ថានធុរកិច្ច និងវិនិយោគ និងសម្រាប់រឹតបន្តឹងវិធានការបំបាត់អំពើរត់ពន្ធគយ ។

- បន្តកែលម្អនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ- ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុម-ហ៊ុននាំចេញ- ចូល និងក្រុមហ៊ុនដើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និងភាពងាយស្រួល ក្នុងការត្រួតពិនិត្យ និងក្នុងការយកពន្ធ និងអាករផ្សេងៗ ។

- បន្តរៀបចំកែលម្អនិងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

- បន្តជំរុញការអនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមាន៖

*ក. បន្តពង្រឹងការអនុវត្តបណ្តាវិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ* ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងកម្លាំងប្រដាប់អាវុធ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តការងាររបស់ខ្លួនឱ្យកាន់តែខ្លាំងក្លា និងប្រកបដោយប្រសិទ្ធភាពថែមទៀត ក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងការអនុវត្តភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ ជាពិសេស លើវិធានការកែលម្អផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេទយិតភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារអេឡិចត្រូនិច និងការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

*ខ. បន្តពង្រឹងការសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និងផ្លាស់ប្តូរព័ត៌មាន* រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និងកាតព្វកិច្ចពន្ធដារ ។

*គ. បន្តរិះរក និងដាក់ឱ្យអនុវត្តនូវវិធានការច្បាស់លាស់ និងទន់ភ្លន់* លើមុខទំនិញមួយចំនួន ដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និងរដ្ឋាករមានជាអាទិ៍ៈ បន្តការបណ្តុះ-បណ្តាល និងការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និងសីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលគយ ឱ្យបានរឹងមាំ ។

- បន្តពង្រឹង និងពង្រីកការអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និងយន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលម្អប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងលើកកំពស់គុណភាពសេវាកម្ម ជូនដល់អតិថិជន ។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ទី៣- ផ្នែកចំណូលមិនមែនសារពើពន្ធៈ**

- បន្តជំរុញការដាក់ឱ្យអនុវត្តបង្កាន់ដៃបង់ប្រាក់សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទនៅតាមគ្រប់ក្រសួង- ស្ថាប័ន ក្នុងគោលដៅបង្កើនការគ្រប់គ្រង និងការប្រមូលចំណូល ។

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពិសេស បទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។ បន្តជំរុញការពង្រឹងការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីធានាឱ្យមានការបង់ចំណូលទាំងនេះចូលថវិការដ្ឋឱ្យបានទៀងទាត់ ទាន់ពេលវេលា និងដោយគ្មានការកាត់ទុកសម្រាប់ចំណាយដោយប្រការណាមួយឡើយ ។

- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និងបណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និងចំណូលពីការជួលរោងចក្រសហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភ័ណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលចំណូល ។

- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសម្បទាន និងពង្រឹងកិច្ចដំណើរការផ្តល់ និងគ្រប់គ្រងកិច្ចសន្យាសម្បទានគ្រប់ប្រភេទទាំងអស់ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីកិច្ចសន្យា សម្បទានគ្រប់ប្រភេទចូលថវិកាជាតិ ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

**១៧-** ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសម្រាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ នៅក្នុងបរិការណ៍នេះ រាជ-រដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលានូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចាប់ផ្តើមការចរចា និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ជាមួយក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្ត ទាំងអស់ចាប់ពីថ្ងៃទី ០១ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឱ្យបាននៅក្នុងសប្តាហ៍ទី ១ នៃ ខែតុលា ឆ្នាំ ២០១១ ដើម្បី គណៈរដ្ឋមន្ត្រីពិនិត្យ និងសម្រេច ហើយផ្ញើជូនរដ្ឋសភាឱ្យបានក្នុងសប្តាហ៍ទី ១ នៃ ខែវិច្ឆិកា ឆ្នាំ ២០១១ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិ មានពេលគ្រប់គ្រាន់ក្នុងការពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះឱ្យបាន មុនថ្ងៃទី ២៥ ខែ ធ្នូ ២០១១ ។

### គ- បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២

**១៨-** ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានធ្វើឱ្យប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំនូវការគ្រប់គ្រងចំណូល និងចំណាយ ពិសេស រាជរដ្ឋាភិបាលបានដោះស្រាយបំណុលចាស់ទាំងស្រុង និងបានបញ្ឈប់ប្រពៃណីខ្វះសាច់ប្រាក់ទូទាត់ចំណាយផងដែរ ។ ទោះជាយ៉ាងនេះក៏ដោយ យើងនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តជំរុញ ជាពិសេស ភាពចាំបាច់ក្នុងការបង្កើនចំណូលពន្ធដារក្នុងស្រុក ដើម្បីបំពេញនិន្នាការថយចុះនៃចំណូលពន្ធនាំចូល និងតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់ ដែលរួមមានដូចជា៖

*ទី១-* ការបន្តជំរុញការយកចិត្តទុកដាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឱ្យបានសមស្រប ដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ហើយពង្រឹងការរៀបចំថវិកាឱ្យបានគ្រប់ជ្រុងជ្រោយ និងសុក្រឹត ដើម្បីកាត់បន្ថយជាអតិបរមានូវចំណាយមិនបានគ្រោងទុក និងសំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និងចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយភាពជឿទុកចិត្តបាន គណនេយ្យភាព និងប្រសិទ្ធភាព ។

*ទី២-* ការបន្តជំរុញការរៀបចំផែនការលទ្ធកម្ម និងកម្មវិធីចំណូល- ចំណាយឱ្យបានសុក្រឹត និងការអនុវត្តឱ្យបានម៉ឺងម៉ាត់ ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅពង្រឹងការគ្រប់គ្រង

សាច់ប្រាក់ ធានាបង្កើនភាពជឿទុកចិត្តបាន និងគណនេយ្យភាពលើការអនុវត្តថវិកា ។ លើសពីនេះ ត្រូវបង្កើនការគោរពយ៉ាងម៉ឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងវិន័យថវិកាទាំង ១០ ។

*ទី៣-* ការបន្តពង្រឹងការគ្រប់គ្រងបំណុល ពិសេស ការកសាងទិន្នន័យ និងការរៀបចំកម្មវិធីសងបំណុលឱ្យបានច្បាស់លាស់ និងដោយផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំថវិកា និងការបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវការខ្ចីតែឥណទានសម្បទាន និងដែលបម្រើឱ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ។

*ទី៤-* បន្តបង្កើនចំណាយលើវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ជាពិសេស ចំពោះគោលនយោបាយអាទិភាព ដូចជា អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ និង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធស្រោចស្រព ដែលជាគោលបំណងនៃគោលនយោបាយ និងជាទិសដៅយុទ្ធសាស្ត្រអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

*ទី៥-* ការបន្តត្រៀមលក្ខណៈដើម្បីទប់ទល់នឹងបញ្ហាប្រឈមថ្មីដូចជា សម្ពាធអតិផរណា តម្រូវការចំណាយសម្រាប់ការការពារអធិបតេយ្យភាព និងបូរណភាពទឹកដី តម្រូវការចំណាយសម្រាប់ការងារបោះឆ្នោតព្រឹទ្ធសភា និងក្រុមប្រឹក្សាឃុំ- សង្កាត់ តម្រូវការចំណាយសម្រាប់កិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំផ្សេងៗដែលចេះតែកើនឡើងទាំងក្នុង និងក្រៅប្រទេស ព្រមទាំងតម្រូវការចំណាយសម្រាប់ដោះស្រាយគ្រោះធម្មជាតិជាយថាហេតុ ។

## IV- នីតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០១២

### ក- ការគ្រោងចំណូលថវិកាឆ្នាំ ២០១២

**១៩-** ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬ ផលទុនដែលជាប្រភពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងបណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ÷

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
    - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ។
    - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ ។
    - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ចនៅពេលខាងមុខ ។
    - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ ។
    - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយ និងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ ។

- ចំពោះចំណូលមិនមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជា កិច្ចសន្យាសម្បទាន កិច្ចសន្យាលក់ ឬដោះដូរ និងកិច្ចសន្យាជួលគ្រប់ប្រភេទ គោលការណ៍ និងការកំណត់នានា

ដែលពាក់ព័ន្ធនឹងការយកកម្រៃផ្សេងៗ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារ និងការពង្រឹង និងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាដើម ។ល។

**ខ- ការគ្រោងចំណាយថវិកាឆ្នាំ ២០១២**

២០- ការរៀបចំគម្រោងឥណទានចំណាយថវិកា ត្រូវផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែលបានផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគណនាតម្រូវការថវិកាដោយលម្អិតទៅតាមជំពូក គណនី និង អនុគណនី និងទៅតាមនាយកដ្ឋាន និងអង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះឱ្យក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត (តាមគំរូដែលភ្ជាប់មកជាមួយស្រាប់) ដោយផ្អែកលើតម្រូវការជាក់ស្តែង និង ដោយផ្ទាល់ សម្រាប់បម្រើឱ្យការអនុវត្តកម្មវិធីសកម្មភាពចាំបាច់ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ រីឯការគណនាឥណទានចំណាយ ត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជាតារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតម្លៃសម្ភារៈនៃការផ្គត់ផ្គង់ និងត្រូវផ្អែកទៅតាមធម្មនិយាមចំណាយ ដែលបានកំណត់នៅក្នុងប្រកាស ឬ សេចក្តីណែនាំ ដូចជា ចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សាសម្រាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសម្រាប់ការគ្រប់គ្រងកន្លងមក ។ ជាពិសេស តម្រូវការចំណាយនីមួយៗ ត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និងមានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់ទៅតាម ជំពូក គណនី និង អនុគណនីនីមួយៗ ។

**គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០១២**

២១- រាជរដ្ឋាភិបាលបានធ្វើការកំណត់នូវកញ្ចប់ថវិកា ដោយកំណត់គោលការណ៍ចំណាយទៅតាមប្រភេទ និងជំពូក ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកា សម្រាប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ធ្វើជាមូលដ្ឋានក្នុងការរៀបចំគម្រោងចំណាយលម្អិតទៅតាមគណនី និងអនុគណនី និងទៅតាមនាយកដ្ឋាន និងអង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដើម្បីបម្រើឱ្យតម្រូវការជាក់ស្តែងក្នុងការអនុវត្តកម្មវិធីសកម្មភាពចាំបាច់ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ដូចជាឆ្នាំមុនៗដែរ ក្នុងរយៈពេលអនុវត្តថវិកានៃឆមាសទី ១ ឆ្នាំ ២០១២ នេះ នឹងមិនមានការអនុញ្ញាតឱ្យធ្វើនិយ័តភាពផ្ទេក្នុងថវិការបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ទេ ។

២២- ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និងបណ្តាវិធានការដូចខាងក្រោម៖

**ក-** ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤) ត្រូវគ្រោងដោយបង្កើន ២០% លើបៀវត្សមូលដ្ឋាន ទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០១១ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោង

ដោយឡែក ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត មិនត្រូវគិតអតិផរណានៅក្នុងចំណាយបៀវត្ស នេះទេ ។ ចំពោះ បុគ្គលិកអណ្តែត និងភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវ ស្នើសុំការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ជ្រើសរើស និងប្រើប្រាស់ ។

ខ- ចំណាយសម្រាប់ការទិញ និងសេវា (ជំពូក ៦០ ៦១ និង ៦២) ត្រូវគ្រោងប្រកបដោយលក្ខណៈ ត្បិតត្បៀត និងសន្សំសំចៃបំផុត ពិសេសលើមុខសញ្ញាទិញសម្ភារៈបរិក្ខារទំនើបៗ គ្រឿងសង្ហារឹមប្រណិតៗ ការជួសជុលធំៗ ព្រមទាំងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ និងការទទួលភ្ញៀវ គឺត្រូវកាត់ចេញនូវមុខចំណាយដែលលែងត្រូវការ ឬ មុខចំណាយដែលបម្រើឱ្យ សកម្មភាពដែលបានបញ្ចប់ ហើយប្រសិនបើមានសកម្មភាពថ្មី ឬមុខចំណាយថ្មីក៏មិនអនុញ្ញាតឱ្យគ្រោងលើស ពីកញ្ចប់ថវិកាក្នុងច្បាប់ឆ្នាំ ២០១១ ដែរ ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនឱ្យមានចំណាយលើស ពីឥណទានថវិកាដែលបានគ្រោងសម្រាប់មុខសញ្ញានេះ និង ហាមដាច់ខាតមិនឱ្យមានការជំពាក់បំណុល ដោយខ្ចីទំនិញ ឬសេវាមកប្រើប្រាស់នៅក្រៅបរិបថថវិកាឡើយ ។ កន្លងមកចំណាយសម្រាប់មុខសញ្ញាអគ្គិសនី ទូរស័ព្ទ ទឹក ប្រេងឥន្ធនៈ និងការទទួលភ្ញៀវ មានលក្ខណៈខ្ជះខ្ជាយ ។ ចំណាយសម្រាប់មុខសញ្ញាទាំងនេះ ចេះតែកើនឡើងហើយការទូទាត់មិនបានទាន់ ពេលវេលាដែលនាំឱ្យមានបំណុលកកស្ទះពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហានេះ ចំពោះចំណាយ អគ្គិសនី ទូរស័ព្ទ និង ទឹកត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នទាំងអស់ ត្រូវសហការត្រួតពិនិត្យលើការ ប្រើប្រាស់បច្ចុប្បន្ន ដើម្បីរៀបចំយន្តការ និងប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និងទឹក ឱ្យបាន ត្រឹមត្រូវ ម៉ត់ចត់ និងប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីរកឃើញការលួចបន្តចរន្តអគ្គិសនី ទូរស័ព្ទ និងទឹក ប្រើប្រាស់ផ្ទាល់ខ្លួនខុសមុខសញ្ញារបស់ក្រសួង-ស្ថាប័នណាមួយ រដ្ឋមន្ត្រីក្រសួងនោះ គឺជាអ្នកទទួលខុសត្រូវ ចំពោះមុខនាយករដ្ឋមន្ត្រី និងចំពោះមុខរដ្ឋសភា ។ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និងក្រុមហ៊ុនទូរស័ព្ទ ត្រូវកាត់ផ្តាច់បណ្តាញលួចលាក់ទាំងនោះភ្លាម ហើយធ្វើរបាយការណ៍ជូនក្រសួងអាណាព្យាបាលបច្ចេកទេស និង ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និងចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នទាំងអស់ ត្រូវសហការគ្រោងឥណទានសម្រាប់ អគ្គិសនី ទូរស័ព្ទ និងទឹក ប្រកបដោយភាពសន្សំសំចៃខ្ពស់ ដោយយកចំណាយជាក់ស្តែងពីឆ្នាំមុន ធ្វើជាពិតាន ហើយកាត់បន្ថយចំណាយមុខសញ្ញានេះឱ្យចុះមកនៅក្នុងកម្រិតមួយសមស្រប តាមការចាំបាច់ ពិតប្រាកដ របស់ក្រសួង-ស្ថាប័ន ។

- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និងក្រុមហ៊ុនផ្តល់ សេវាទូរស័ព្ទ ត្រូវផ្តល់វិក្កយបត្រប្រចាំខែនីមួយៗ ឱ្យបានមុនថ្ងៃទី ១៥ នៃខែ បន្ទាប់ ។ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់វិក្កយបត្រ និងរៀបចំទូទាត់ឱ្យបានទៀងទាត់ និងទាន់ ពេលវេលារៀងរាល់ខែ ។ ហាមដាច់ខាតមិនឱ្យមានការពន្យារការទូទាត់លើមុខសញ្ញាចំណាយនេះ ដោយ យកឥណទាននេះទៅប្រើប្រាស់លើមុខសញ្ញាផ្សេង ហើយផ្ទេរបន្ទុកនេះបកលើថវិការួមទេ ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវស្នើឡើងនូវវិធានការជាក់លាក់ ក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និងទឹក ដើម្បីដាក់ជូនប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ហើយដាក់ឱ្យគ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលអនុវត្តឱ្យបានខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់បំផុត ។

**គ-** ចំណាយសម្រាប់ការឧបត្ថម្ភកធន និងជំនួយសង្គម (ជំពូក ៦៥) ត្រូវគ្រោងទៅតាមតម្រូវការចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ចំពោះចំណាយដែលក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តត្រូវអនុវត្តដោយផ្ទាល់ ត្រូវគ្រោងទៅតាមគោលការណ៍ ឬ កិច្ចសន្យា ដែលជាកាតព្វកិច្ចរបស់រដ្ឋ និងនៅជាធរមាន ហើយចំណាយនេះត្រូវគ្រោងយ៉ាងច្រើនស្មើនឹងកញ្ចប់ថវិកាក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ លើកលែងតែមានគោលនយោបាយ គោលការណ៍ ឬកិច្ចសន្យាថ្មី ។ ដោយឡែកចំពោះចំណាយដែលត្រូវអនុវត្តដោយអង្គភាពស្វយ័ត ឬអង្គភាពដែលមានថវិកាដោយឡែក ត្រូវគ្រោងដោយផ្អែកលើគោលការណ៍តាមជំពូកដែលបានកំណត់នៅក្នុងចំណុច **ក** និង **ខ** ខាងលើ ។ ចំពោះ ក្រសួង-ស្ថាប័ន ដែលត្រូវបន្ត ឬចាប់ផ្តើមអនុវត្តសាកល្បងថវិកាកម្មវិធី ត្រូវញែកគម្រោងចំណាយជាពីរផ្នែក សម្រាប់ថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធី ទៅតាមគ្រប់ជំពូក គណនី និងអនុគណនីនីមួយៗ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអញ្ជើញក្រសួងទាំងនេះ មកការពារគម្រោងថវិកាកម្មវិធីដោយឡែក ។

**ឃ-** ឯកសារផែនការយុទ្ធសាស្ត្រថវិកា គម្រោងចំណូល និងគម្រោងចំណាយថវិកា ដែលក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាមូលដ្ឋានសម្រាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំការពារថវិកា ដើម្បីការពារកញ្ចប់ថវិការបស់ខ្លួន ។ ដូច្នេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត ដែលមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់ការប្រជុំការពារថវិកាទេ នោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅក្រសួង-ស្ថាប័ន ឬ មន្ទីរជំនាញរាជធានី-ខេត្តនោះ ឱ្យបានទាន់ពេលវេលា ដើម្បីធ្វើការបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃថវិកាឆ្នាំ ២០១១ ហើយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូក គណនី និងអនុគណនីខាងលើ សម្រាប់កំណត់គម្រោងថវិការបស់ក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្តនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការប្រជុំការពារថវិកា និងរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា ។

### ឃ-ការរៀបចំ និង ការចិត្តគស័ណើនានា

**២៣-** ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (n-1) ឆ្នាំ ២០១១ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២១០/០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០១២ ឆ្នាំ (n) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន ។ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និងការណែនាំទាំងឡាយខាងលើនេះ សម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម ÷

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា÷

- ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី-ខេត្តមានការប្រែប្រួល ។
- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ។

• ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និងចំណាយរដ្ឋបាល ។ល។

២៤- គម្រោងថវិការបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែមត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយ នូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបានលុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៥- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួលអាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៦- បច្ចេកទេសវិភាគដ៏ទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និងអត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ត្រូវតែបម្រើទៅលើៈ

- ទិសដៅ និងគោលបំណងនៃគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។
- កម្មវិធី និងយុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ច្បាស់លាស់ ដើម្បីសម្រេចបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។
- ផែនការសកម្មភាព និងរាល់មធ្យោបាយដំណើរការ ដើម្បីអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ។
- ការគ្រប់គ្រង ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍ដើម្បីបង្ហាញពីលទ្ធផលនៃការអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ដែលជាមូលដ្ឋានសម្រាប់សម្រេចបានគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។

## V- សេចក្តីសន្និដ្ឋាន

២៧- ខ្លឹមសារនៃសារាចរណែនាំនេះ បានផ្តល់នូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងគោលការណ៍ និងនីតិវិធីក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជាមូលដ្ឋាន ដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួនឱ្យឆ្លើយតបទៅនឹងកម្មវិធី យុទ្ធសាស្ត្រអាទិភាព ព្រមទាំងទិសដៅ និងគោលបំណងនៃគោល-នយោបាយតាមវិស័យ និងតាមផ្នែករៀងៗខ្លួន សំដៅបម្រើឱ្យបានសម្រេចនូវគោលដៅ **ផែនការយុទ្ធសាស្ត្រ**

**អភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣** ក៏ដូចជាគោលដៅនៃ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យគឺ ការរក្សាកំណើនប្រកបដោយចីរភាពក្នុងរង្វង់ប្រមាណ ៧% និងការកាត់បន្ថយភាពក្រីក្រឱ្យបានជាង ១% ក្នុងមួយឆ្នាំៗ ព្រមទាំងការបន្តរក្សា ឱ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុត ក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ***ភាពសុខដុមរមនាសង្គម និង សុខុមាលភាពរបស់ប្រជាជន*** ។ ដូច្នេះ ដើម្បីឱ្យធនធាននេះអាចប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់នោះ ទាមទារឱ្យគ្រប់ក្រសួង- ស្ថាប័នទាំងអស់មានទិសដៅ និងគោលបំណងនៃគោលនយោបាយរបស់ខ្លួនយ៉ាងច្បាស់លាស់ដែលផ្សារភ្ជាប់ទៅនឹង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ-បច្ចុប្បន្នកម្ម ២០០៩-២០១៣** មានកម្មវិធី និងយុទ្ធសាស្ត្រអាទិភាពជាក់លាក់ ព្រមទាំងផែនការសកម្មភាពត្រឹមត្រូវ ក្នុងការអនុវត្តឆ្ពោះទៅសម្រេចឱ្យបាននូវគោលបំណង និងទិសដៅនៃគោលនយោបាយរបស់ខ្លួន ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ជាពិសេស ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ។

២៨- ពេលទទួលបានសារាចរណែនាំនេះ ***គ្រប់ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្ត ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល- ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួនពីរច្បាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១*** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាកម្រិតជំនាញ និងបូកសរុបសម្រាប់ការចរចាចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១ ។ តួលេខគម្រោងចំណូល- ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម 0,1 លានរៀល ។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្ត មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

***«ដើម្បីជូនជ្រាប»***

- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
- គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

***«ដើម្បីមុខការ»***

- ឯកសារ-កាលប្បវត្តិ